ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំង សមាសភាព នៃគណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

### សម្រេច

**ប្រការ១:** ត្រូវបានតែងតាំងជាសមាជិកភាពនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- សម្តេចកិត្តិព្រឹទ្ធបណ្ឌិត | **ប៊ុន រ៉ានី ហ៊ុន សែន** | | ប្រធានកិត្តិយស |
| ២- លោកជំទាវវេជ្ជ. | **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | ប្រធាន |
| ៣- លោកជំទាវ | **ហ៊ូ សាមិត្ត** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោកជំទាវ | **ឆ៊ិញ កុសលី** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥- លោកជំទាវ | **ច័ន្ទ ធី** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | អនុប្រធាន |
| ៦- លោកជំទាវ | **ងួ ម៉ិនអេង** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៧- លោកជំទាវ | **ស៊ើង សរសុចិត្តា** | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៨- លោកជំទាវ | **ឆាន់ សុផាវី** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិកា |

| | | | |
|---|---|---|---|
| ៩- លោកជំទាវ | **សម មុន្នីកា** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិកា |
| ១០- លោកជំទាវ | **ទូច សារ៉ុម** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិកា |
| ១១- លោកជំទាវ | **ម៉ាលី សុជាតា** | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិកា |
| ១២- លោកជំទាវ | **មាសសាឯម ជានី** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកា |
| ១៣- លោកជំទាវ | **កែវ ចរិយា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកា |
| ១៤- លោកជំទាវ | **ជ្រឹម មុន្នីរទេវី** | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិកា |
| ១៥- លោកជំទាវ | **ច័ន្ទ ហារ៉ាន់វឌ្ឍី** | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ១៦- លោកជំទាវ | **ឆន់ សារុ៊ីម** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៧- លោកជំទាវ | **យ៉ែយ នីតា** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិកា |
| ១៨- លោកជំទាវ ឧត្តមសេនីយ៍ឯក | **យក់ សុខា** | អគ្គស្នងការរងនគរបាលជាតិ | សមាជិកា |
| ១៩- លោក វរសេនីយ៍ឯក | **ស៊ិន ស៊ីថា** | នាយការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌ បញ្ជាការដ្ឋានកងរាជអាវុធហត្ថ | សមាជិក |
| ២០- លោកស្រី | **ម៉ក់ ចន្ទណ្ណស៊ីថា** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិកា |

**ប្រការ២:** សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ មានភារកិច្ចអនុវត្តការងារ ទៅតាមការតម្រង់ទិសដៅនៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ទទួលបានលទ្ធផលល្អប្រសើរ និងអញ្ជើញចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ